ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្តបាត់ដំបង
រដ្ឋបាលស្រុកថ្មគោល
លេខៈ០៧/២១.ដក/សថគ

--------------------

# ដីកា
## ស្តីពី
## ការលើកកម្ពស់សុវត្ថិភាព និងសុខុមាលភាពចំណីអាហារនៅតាមគ្រឹះស្ថានសិក្សា ក្នុងស្រុកថ្មគោល ខេត្តបាត់ដំបង

## ក្រុមប្រឹក្សាស្រុកថ្មគោល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខ័ណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទីភារកិច្ចនិងការទំនាក់ទំនងការងារក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- បានឃើញអនុក្រឹត្យលេខ ២៨៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីនីតិវិធីសម្រាប់ការរៀបចំ ការកែប្រែ និងការលុបចោលដីកាក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាខណ្ឌ/.

- បានឃើញអនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥ ស្ដីពីការគ្រប់គ្រងសំរាម និងសំណល់រឹងទីប្រជុំជន
- បានឃើញអនុក្រឹត្យលេខ៩៨០ អនក្រ.តត ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៩ របស់រាជរដ្ឋាភិបាលកម្ពុជា ស្ដីពីការទទួលស្គាល់សមាសភាពក្រុមប្រឹក្សាអាណត្តិទី៣របស់ស្រុកថ្មគោល ខេត្តបាត់ដំបង
- បានឃើញសេចក្ដីណែនាំអន្តរក្រសួងលេខ ១៤១១ ស.ជ.ណ.ប.ស្ល. ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ស្ដីពីការអនុវត្តមុខងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- បានឃើញសេចក្ដីណែនាំលេខ១៨ អយក.សណន ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៣ ស្ដីពីការលើកកម្ពស់សុវត្ថិភាពចំណីអាហារ និងអាហារប្រកបដោយសុខភាពនៅតាមគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន
- បានឃើញសេចក្ដីណែនាំលេខ ៣៦៣៧ អយក/ស.ណ.ន ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៤ ស្ដីពីការលើកកម្ពស់សុខភាពអនាម័យ និងសុវត្ថិភាពចំណីអាហារតាមសាលារៀន
- បានឃើញសេចក្ដីណែនាំលេខ១៨ អយក.ស.ណ.ន ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៩ ស្ដីពីការពង្រឹងវិធានការអនុវត្តការលើកកម្ពស់សុវត្ថិភាពនិងសុខុមាលភាពចំណីអាហារតាមគ្រឹះស្ថានសិក្សាចំណេះទូទៅ និងឯកជន
- យោងសេចក្ដីសម្រេចកិច្ចប្រជុំសាមញ្ញក្រុមប្រឹក្សាស្រុកលើកទី៥ អាណត្តិទី៣ កាលពីថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៩ ស្ដីពីការអនុម័តលើសេចក្ដីព្រាងការកំណត់បញ្ហាដែលបានមកពីវេទិកាក្រុមប្រឹក្សាស្រុក
- យោងសេចក្ដីសម្រេចកិច្ចប្រជុំសាមញ្ញក្រុមប្រឹក្សាស្រុកលើកទី៧ អាណត្តិទី៣ កាលពីថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៩ ស្ដីពីការពិនិត្យនិងអនុម័តលើសេចក្ដីព្រាងរបាយការណ៍ចុះប្រមូលព័ត៌មានលើកកម្ពស់សុខុមាលភាពកុមារ
- យោងសេចក្ដីសម្រេចកិច្ចប្រជុំសាមញ្ញក្រុមប្រឹក្សាស្រុកលើកទី៨ អាណត្តិទី៣ កាលពីថ្ងៃទី៣០ ខែមករា ឆ្នាំ២០២០ ស្ដីពីការពិនិត្យនិងអនុម័តលើផែនការលើកកម្ពស់សុខុមាលភាពកុមារ
- យោងកិច្ចប្រជុំសាមញ្ញលើកទី ២០ របស់ក្រុមប្រឹក្សាស្រុកអាណត្តិទី ៣ កាលពីថ្ងៃព្រហស្បតិ៍ ៧ រោចខែមាឃ ឆ្នាំ ជូត ទោស័កព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី ០៤ ខែកុម្ភៈ ឆ្នាំ ២០២១ ។

## **សម្រេច**

--------------------

## **ជំពូកទី១**
## **បទប្បញ្ញត្តិទូទៅ**

**ប្រការ១**.-

ដីការនេះមានគោលបំណងលើកកម្ពស់សុវត្ថិភាព និងសុខុមាលភាពចំណីអាហារតាមគ្រឹះស្ថានសិក្សាក្នុងស្រុកថ្មគោលឲ្យទទួលបាននូវស្ថានភាពកាន់តែប្រសើរឡើងតាមរយៈការលើកកម្ពស់ផ្នែកសណ្ដាប់ធ្នាប់ អនាម័យ

ជាពិសេសផ្តោតលើសុវត្ថិភាព និងសុខុមាលភាពចំណីអាហារដែលលក់ខាងក្នុងបរិវេណ និងជាប់ខាងក្រៅបរិវេណគ្រឹះស្ថានសិក្សា ។

**ប្រការ២**.-

ដីកានេះមានគោលដៅដូចខាងក្រោម៖

១) ពង្រឹងនូវយន្តការដែលមានស្រាប់របស់សាលា(គណៈកម្មការសុខភាពសិក្សា និងគណៈកម្មការគ្រប់គ្រងសាលា) ទទួលបាននូវឱកាសសមស្របក្នុងការអនុវត្តតួនាទីភារកិច្ចរបស់ខ្លួនដោយផ្តោតលើផ្នែកសណ្តាប់ធ្នាប់ អនាម័យ សុវត្ថិភាព និងសុខុមាលភាពចំណីអាហារដែលលក់ខាងក្នុងបរិវេណនិងជាប់ខាងក្រៅបរិវេណគ្រឹះស្ថានសិក្សា ។

២) បង្កើនចំណេះដឹងដល់អ្នកពាក់ព័ន្ធរួមទាំងនាយក/នាយិកាសាលា លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស អាណាព្យាបាលសិស្ស អាជ្ញាធរដែនដី សមត្ថកិច្ច មណ្ឌលសុខភាព និងអ្នកលក់ចំណីអាហារនៅខាងក្នុងបរិវេណ និងជាប់ខាងក្រៅបរិវេណគ្រឹះស្ថានសិក្សាឲ្យយកចិត្តទុកដាក់ខ្ពស់ទាក់ទងនឹងសណ្តាប់ធ្នាប់ អនាម័យ សុវត្ថិភាព និងសុខុមាលភាពចំណីអាហារទាំងនោះ ។

៣) ពង្រឹងប្រសិទ្ធភាពក្នុងការអនុវត្តដីកា ដល់អ្នកពាក់ព័ន្ធ ពិសេសអ្នកលក់ដូរចំណីអាហារ និងភេសជ្ជៈក្នុងបរិវេណ និងនៅជាប់ខាងក្រៅបរិវេណគ្រឹះស្ថានសិក្សា ។

**ប្រការ៣**.-

ដីកានេះមានវិសាលភាព សម្រាប់យកទៅអនុវត្តនៅតាមគ្រឹះស្ថានសិក្សា ដែលស្ថិតនៅក្រោមការគ្រប់គ្រងក្នុងដែនសមត្ថកិច្ចនៃស្រុកថ្មគោលតែប៉ុណ្ណោះ ។

**ប្រការ៤**.-

វាក្យស័ព្ទដែលប្រើក្នុងដីកានេះត្រូវបានកំណត់និយមន័យដូចខាងក្រោម៖

- **ដីកា** ៖ គឺជាប្រភេទលិខិតបទដ្ឋានគតិយុត្តដាក់ចេញដោយរដ្ឋបាលថ្នាក់ក្រោមជាតិ (ដោយមានការសម្រេចពីក្រុមប្រឹក្សា)។
- **សុខុមាលភាព៖** គឺសំដៅដល់ដំណើរមិនមានរោគា មានភាពសុខស្រួលទាំងផ្លូវកាយនិងផ្លូវចិត្ត ។
- **ដែនសមត្ថកិច្ច៖** គឺជាតំបន់ ជាមុខងារ និងជាភារកិច្ចដែលស្ថិតនៅក្រោមសិទ្ធិអំណាចក្រុមប្រឹក្សា ។
- **គ្រឹះស្ថានសិក្សា៖** គឺសំដៅដល់គ្រឹះស្ថានសិក្សាចំណេះទូទៅសាធារណៈនិងឯកជន ដែលបានផ្ទេរតាមរយៈការប្រគល់ និងការធ្វើប្រតិភូកម្មដល់រដ្ឋបាលស្រុក ។
- **យន្តការមានស្រាប់** ៖ គឺសំដៅដល់គណៈកម្មការនានាដែលមានស្រាប់នៅតាមគ្រឹះស្ថានសិក្សា។
- **នគរបាលយុត្តិធម៌៖** គឺសំដៅដល់មន្ត្រីនគរបាលយុត្តិធម៌ ភ្នាក់ងារនគរបាលយុត្តិធម៌ និងមន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត ដែលច្បាប់កំណត់ដោយឡែក ប្រគល់អំណាចឲ្យធ្វើការពិនិត្យបទល្មើសខ្លះៗក្នុងវង្វង់សមត្ថកិច្ចរបស់ខ្លួន ។ នគរបាលយុត្តិធម៌គឺជាជំនួយរបស់អំណាចតុលាការ ។

- **លិខិតបទដ្ឋានគតិយុត្តៈ** ជាលិខិតដែលកំណត់ជាក្បួនច្បាប់មានអានុភាពគតិយុត្តចាប់បង្ខំឲ្យអនុវត្ត ក្នុងការគ្រប់គ្រងសង្គម គ្រប់គ្រងរដ្ឋលើគ្រប់វិស័យ ។ លិខិតគតិយុត្តចែកចេញជា២ប្រភេទគឺ លិខិតមានលក្ខណៈជាបទបញ្ញត្តិទូទៅ និងលិខិតគតិយុត្តមានលក្ខណៈជាឯកត្តភូតសម្រាប់ការតែងតាំង ។

## ជំពូកទី២
## អំពី
## តួនាទី ភារកិច្ច ការទទួលខុសត្រូវ និងភាគព្វកិច្ចអ្នកពាក់ព័ន្ធ

**ប្រការ៥**.-

ដើម្បីសម្រេចបាននូវគោលបំណង និងគោលដៅខាងលើ និងដើម្បីឲ្យការអនុវត្តដីកានេះមានប្រសិទ្ធភាពខ្ពស់ រដ្ឋបាលស្រុកថ្មគោលមានតួនាទី និងការទទួលខុសត្រូវដូចខាងក្រោមៈ

- ពង្រឹងកិច្ចសហការនិងទំនាក់ទំនងល្អជាមួយនគរបាលយុត្តិធម៌ និងអង្គភាព ស្ថាប័នពាក់ព័ន្ធនានា
- ធានាថាដីកាត្រូវបានផ្សព្វផ្សាយយ៉ាងទូលំទូលាយនិងអនុវត្តក្រោយពីដីកានេះបានចូលជាធរមាន
- បញ្ចូលគោលដៅលើកកម្ពស់សុវត្ថិភាព និងសុខុមាលភាពចំណីអាហារក្នុងផែនការ៥ឆ្នាំរដ្ឋបាលស្រុក
- រៀបចំឲ្យមានកញ្ចប់ថវិកាដោយឡែក និងស្វែងរកការគាំទ្រពីបណ្តាដៃគូទាំងលើផ្នែកបច្ចេកទេស និងថវិកា ក្នុងការអនុវត្តផែនការក៏ដូចជាអនុវត្តដីកានេះឲ្យមានប្រសិទ្ធភាព
- ពង្រឹងសមត្ថភាពយន្តការដែលមានស្រាប់របស់សាលា និងធានាឲ្យមានការអនុវត្ត ភារកិច្ចឲ្យបានពេញលេញ
- លើកទឹកចិត្តឲ្យមានការចូលរួមពេញលេញពីគ្រប់មជ្ឈដ្ឋាន និងអ្នកពាក់ព័ន្ធ ក្នុងការអនុវត្តដីកា
- ធានាឲ្យមានកិច្ចប្រជុំជាមួយអ្នកពាក់ព័ន្ធ ដើម្បីពិភាក្សា និងរកដំណោះស្រាយលើបញ្ហាបានកើតឡើងទាក់ទងនិងសណ្តាប់ធ្នាប់ អនាម័យ សុវត្ថិភាព និងសុខុមាលភាពចំណីអាហារដែលលក់នៅតាមគ្រឹះស្ថានសិក្សានីមួយៗ
- ឃ្លាំមើលពីការវិវត្តន៍ ការផ្លាស់ប្តូរ ជុំវិញការអនុវត្តដីកានៅតាមគ្រឹះស្ថានសិក្សានីមួយៗ
- ធានាថាព័ត៌មានជុំវិញការលើកកម្ពស់សុវត្ថិភាព និងសុខុមាលភាពចំណីអាហារ និងដំណើរការអនុវត្តដីកា ត្រូវបានរាយការណ៍ជូនក្រុមប្រឹក្សាស្រុកជាប្រចាំ និងផ្សព្វផ្សាយតាមហ្វេសប៊ុកផេករបស់រដ្ឋបាលស្រុកនិងផេករបស់ការិយាល័យអប់រំ យុវជន និងកីឡា។

**ប្រការ៦**.-

ការិយាល័យអប់រំ យុវជន និងកីឡាស្រុក ត្រូវបំពេញតួនាទីជាសេនាធិការរបស់រដ្ឋបាលស្រុក សម្របសម្រួលដល់គ្រឹះស្ថានសិក្សានីមួយៗ ដែលមានភារកិច្ចនិងការទទួលខុសត្រូវដូចខាងក្រោមៈ

- ត្រូវអប់រំផ្សព្វផ្សាយ ខ្លឹមសារសេចក្តីណែនាំបន្តដល់គ្រប់គ្រឹះស្ថានសិក្សាក្រោមឱវាទក្នុងការពង្រឹងការអនុវត្តតាមស្មារតីលិខិត ដែលទាក់ទងនិងការលើកកម្ពស់សុវត្ថិភាព និងសុខុមាលភាពចំណីអាហារ/

- ត្រូវជំរុញមន្ត្រីទទួលបន្ទុកការងារសុខភាពសិក្សា ក្នុងការពង្រឹងការគ្រប់គ្រង ការសម្របសម្រួល អប់រំផ្សព្វផ្សាយ ការលើកកម្ពស់សុវត្ថិភាព និងសុខុមាលភាពចំណីអាហារសហការជាមួយអ្នកពាក់ព័ន្ធ
- ត្រូវចាត់តាំងមន្ត្រីឲ្យធ្វើការពិនិត្យតាមដានជាទៀងទាត់ និងធ្វើរបាយការណ៍បូកសរុបលទ្ធផលពីការអនុវត្តការលើកកម្ពស់សុវត្ថិភាពនិងសុខុមាលភាពចំណីអាហាររៀងរាល់ឆមាសនៃឆ្នាំសិក្សានីមួយៗ រួចផ្ញើជូនរដ្ឋបាលស្រុក និងមន្ទីរអប់រំ យុវជន និងកីឡាខេត្ត
- ត្រូវរៀបចំសហការជាមួយអ្នកពាក់ព័ន្ធ ក្នុងការចុះអន្តរាគមន៍បន្ទាន់ដល់គ្រឹះស្ថានសិក្សាករណីមានពុលចំណីអាហារ ឬហានិភ័យសុខភាពផ្សេងទៀត
- ដាក់បញ្ចូលសកម្មភាពលើកកម្ពស់សុវត្ថិភាព និងសុខុមាលភាពចំណីអាហារក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍របស់សាលារយៈពេល៥ឆ្នាំ និងស្វែងរកការគាំទ្រលើបច្ចេកទេស និងថវិកាពីប្រភពខាងក្រៅ មានការលើកទឹកចិត្តដល់គ្រឹះស្ថានសិក្សាដែលមានស្នាដៃល្អ ក្នុងការបំពេញតួនាទី ។

**ប្រការ៧**.-

គ្រប់គ្រឹះស្ថានសិក្សាដែលស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋបាលស្រុក ត្រូវមានភារកិច្ច និងការទទួលខុសត្រូវដូចខាងក្រោម៖

- រៀបចំនិងពង្រឹងការអនុវត្តបទបញ្ជាផ្ទៃក្នុងស្តីពីការលើកកម្ពស់សុវត្ថិភាព និងសុខុមាលភាពចំណីអាហារនៅតាមគ្រឹះស្ថានសិក្សារបស់ខ្លួន (មានចែងក្នុងគំរូឧបសម្ព័ន្ធ១)
- ធ្វើកិច្ចសន្យាស្តីពីការលើកកម្ពស់សុវត្ថិភាព និងសុខុមាលភាពចំណីអាហារជាមួយអ្នកលក់ចំណីអាហារនៅតាមគ្រឹះស្ថានសិក្សា (មានចែងក្នុងគំរូឧបសម្ព័ន្ធ២)
- រៀបចំនិងពង្រឹងយន្តការពិនិត្យតាមដានការដាក់លក់ចំណីអាហារនៅខាងក្នុងបរិវេណនិងជាប់ខាងក្រៅបរិវេណគ្រឹះស្ថានសិក្សា ដោយសហការជាមួយអាជ្ញាធរមានសមត្ថកិច្ច ដើម្បីធានាថាចំណីអាហារត្រូវតែមានសុវត្ថិភាព និងសុខុមាលភាព
- មានវិធានការដកហូតចំណីអាហារដែលមិនមានសុវត្ថិភាពនិងសុខុមាលភាពនៅតាមគ្រឹះស្ថានសិក្សារបស់ខ្លួន(ចែងក្នុងចំណុចខ.១ នៃសេចក្តីណែនាំលេខ១៨ អយក.សណន. ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៩ របស់ក្រសួងអប់រំ យុវជន និងកីឡា ដោយសហការជាមួយអ្នកពាក់ព័ន្ធ
- អប់រំផ្សព្វផ្សាយពីការលើកកម្ពស់សុវត្ថិភាពនិងសុខុមាលភាពចំណីអាហារដល់បុគ្គលិកអប់រំ អ្នកសិក្សា អ្នកលក់ចំណីអាហារ មាតាបិតា អាណាព្យាបាលនិងសហគមន៍នៅតាមគ្រឹះស្ថានសិក្សារបស់ខ្លួនឲ្យបានយ៉ាងតិចមួយត្រីមាសម្តង
- ណែនាំដល់គ្រូបង្រៀន ឲ្យអប់រំផ្សព្វផ្សាយដល់អ្នកសិក្សាជាប្រចាំពីសុវត្ថិភាពនិងសុខុមាលភាពចំណីអាហារ (មានចែងក្នុងចំណុចខ នៃសេចក្តីណែនាំលេខ១៨ អយក.សណន. ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៩ របស់ក្រសួងអប់រំ យុវជន និងកីឡា.

- ប្រជុំនិងលើកទឹកចិត្តអាណាព្យាបាលសិស្ស ឲ្យយកចិត្តទុកដាក់រៀបចំចំណីអាហារប្រកបដោយសុវត្ថិភាព និងសុខុមាលភាពដល់កូន ក្មួយ ឬចៅនៅផ្ទះឲ្យបានត្រឹមត្រូវ និងដើម្បីយកមកបរិភោគនៅគ្រឹះស្ថានសិក្សា
- លើកទឹកចិត្តគ្រូបង្រៀនឲ្យតាមដានការបរិភោគចំណីអាហារ និងស្ថានភាពសុខភាពរបស់សិស្សនៅតាមគ្រឹះស្ថានសិក្សាឲ្យបានជាប្រចាំ
- ធ្វើរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តការលើកកម្ពស់សុវត្ថិភាព និងសុខុមាលភាពចំណីអាហាររៀងរាល់ឆមាសនៃឆ្នាំសិក្សានីមួយៗ រួចផ្ញើជូនការិយាល័យអប់រំ យុវជន និងកីឡាស្រុក
- ធានាឲ្យមានការធ្វើបច្ចុប្បន្នភាព និងមានដំណើរការជាប្រចាំលើយន្តការមានស្រាប់របស់សាលា
- ដាក់បញ្ចូលសកម្មភាពលើកកម្ពស់សុខភាពសិក្សា ទៅក្នុងផែនការអភិវឌ្ឍ៥ឆ្នាំរបស់សាលា
- ស្វែងរកការគាំទ្រលើការបំពាក់នូវឧបករណ៍ផលិតទឹកស្អាត ឧបករណ៍លាងសម្អាតដៃ និងឡដុតសំរាមនៅតាមគ្រឹះស្ថានសិក្សារបស់ខ្លួន
- ចាត់វិធានការថែទាំបរិស្ថាន ការគ្រប់គ្រងសំរាម និងសំណល់រឹងក្នុងគ្រឹះស្ថានសិក្សា តាមរយៈការផ្សព្វផ្សាយចំណេះដឹងដល់អ្នកពាក់ព័ន្ធ និងទំនាក់ទំនងជាមួយក្រុមហ៊ុនដើម្បីប្រមូលសំរាមឲ្យបានទៀងទាត់ និងអនុវត្តការផាកពិន័យដល់អ្នកចោលសំរាមពាសវាលពាសកាល
- ផ្សព្វផ្សាយឲ្យបានទូលំទូលាយពីគោលនយោបាយសុខភាពសិក្សា និងសេចក្តីណែនាំផ្សេងៗទៀតរបស់ក្រសួងអប់រំ យុវជន និងកីឡា ដល់អ្នកពាក់ព័ន្ធ ។

## ជំពូកទី៣
## នីតិវិធីជ្រើសរើសអ្នកលក់ខាងក្នុងបរិវេណ និងជាប់ខាងក្រៅបរិវេណគ្រឹះស្ថានសិក្សា

**ប្រការ៨**.-

អ្នកលក់ចំណីអាហារខាងក្នុងបរិវេណ និងជាប់ខាងក្រៅបរិវេណគ្រឹះស្ថានសិក្សាដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ត្រូវបានជ្រើសរើស នឹងទទួលបានការណែនាំពីលក្ខខណ្ឌនានាមុននឹងចុះកិច្ចសន្យា ។ កិច្ចសន្យានេះត្រូវបានរៀបចំឡើងរៀងរាល់១ឆ្នាំម្តង រវាងអ្នកលក់ចំណីអាហារដែលត្រូវបានជ្រើសរើសជាមួយនឹងគ្រឹះស្ថានសិក្សានោះ ។

**ប្រការ៩**.-

ពុំមានអ្នកលក់ចំណីអាហារណាម្នាក់ ត្រូវបានអនុញ្ញាតឲ្យធ្វើការលក់ចំណីអាហារនៅខាងក្នុងបរិវេណនិងជាប់ខាងក្រៅបរិវេណគ្រឹះស្ថានសិក្សាដោយមិនបានឆ្លងកាត់ការត្រួតពិនិត្យ និងយល់ព្រមពីគ្រឹះស្ថានសិក្សានោះឡើយ (ស្ត្រីមេម៉ាយ ជនពិការ គ្រួសារក្រីក្រ ដែលមានទីលំនៅក្នុងឃុំសាមីត្រូវបានលើកទឹកចិត្ត) ។/

## ជំពូកទី៤
## ទោសប្បញ្ញត្តិ

**ប្រការ១០.-**

អ្នកលក់ចំណីអាហារនៅក្នុងបរិវេណ និងជាប់ខាងក្រៅបរិវេណគ្រឹះស្ថានសិក្សាត្រូវអនុវត្តទៅតាមបទបញ្ជាផ្ទៃក្នុងស្តីអំពីសុវត្ថិភាពចំណីអាហារ ខ្លឹមសារនៃគោលការណ៍ណែនាំ និងសេចក្តីណែនាំនានារបស់ក្រសួងអប់រំ យុវជន និងកីឡា ដោយមិនអនុញ្ញាតឲ្យលក់ប្រភេទចំណីអាហារដែលមានហានិភ័យខ្ពស់ចំពោះសុខភាព ចំណីអាហារដែលបានហាមឃាត់ និងត្រូវអនុវត្តទៅតាមវិធានការអនាម័យក្នុងការដាក់លក់ចំណីអាហារដែលមានចែងនៅក្នុងសេចក្តីណែនាំលេខ១៨ អយក/ស.ណ.ន. ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៣ និងសេចក្តីណែនាំលេខ១៨ អយក/ស.ណ.ន. ចុះថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៩ របស់ក្រសួងអប់រំ យុវជន និងកីឡា ។

**ប្រការ១១.-**

អ្នកលក់ចំណីអាហារ ដែលជាប់កិច្ចសន្យាជាមួយគ្រឹះស្ថានសិក្សា ហើយអនុវត្តមិនបានពេញលេញទៅតាមលក្ខខណ្ឌណាមួយនៃកិច្ចសន្យា លើកទី១ ត្រូវធ្វើការណែនាំផ្ទាល់ពីគណៈគ្រប់គ្រងគ្រឹះស្ថានសិក្សា លើកទី២ ត្រូវព្រមានជាលាយលក្ខណ៍អក្សរ និងលើកទី៣ ត្រូវបញ្ឈប់កិច្ចសន្យាដោយស្វ័យប្រវត្តិ។ ក្នុងករណីរកឃើញថាអ្នកលក់ចំណីអាហារណាដែលបំពាន និងមិនបានអនុវត្តតាមកិច្ចសន្យា គណៈគ្រប់គ្រងគ្រឹះស្ថានសិក្សាត្រូវហាមឃាត់ជាបន្ទាន់ និងត្រូវដកហូតនូវចំណីអាហារដោយសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចដែលមានចែងក្នុងសេចក្តីណែនាំលេខៈ១៨ អយក/ស.ណ.ន. ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៣ និងសេចក្តីណែនាំលេខ១៨ អយក/ស.ណ.ន. ចុះថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៩ របស់ក្រសួងអប់រំ យុវជន និងកីឡា ។

**ប្រការ១២.-**

អ្នកលក់ចំណីអាហារដែលជាប់កិច្ចសន្យានៅតាមគ្រឹះស្ថានសិក្សានីមួយៗត្រូវគ្រប់គ្រងសំរាម និងសំណល់រឹងដែលកើតឡើងពីការលក់ដោយខ្លួនឯង ។

ការបោះចោល ឬចាក់ចោលសំរាម និងសំណល់រឹងរាយប៉ាយតាមដងផ្លូវទីសាធារណៈ ទីប្រជុំជន កន្លែងកំសាន្ត មាត់ស្ទឹង ប្រភពទឹកប្រើប្រាស់ ប្រពន្ធ័បង្ហូរទឹកលូ ប្រពន្ធ័ប្រឡាយ ត្រូវហាមឃាត់ជាដាច់ខាត ។

ជនណាដែលប្រព្រឹត្តិល្មើស ត្រូវទទួលការពិន័យជាប្រាក់ពី១០.០០០រៀល ទៅ១០០.០០០រៀល ។ ក្នុងករណីមិនរាងចាលត្រូវទទួលពិន័យជាប្រាក់ទ្វេដង។មានចែងក្នុងប្រការ៤របស់ប្រកាសអន្តរក្រសួង(ក្រសួងមហាផ្ទៃ និងក្រសួងបរិស្ថាន) ។

**ប្រការ១៣.-**

រាល់បទប្បញ្ញត្ត លិខិតបទដ្ឋានគតិយុត្ត ឬសេចក្តីណែនាំទាំងឡាយណាដែលបានបង្កើតឡើង មានខ្លឹមសារផ្ទុយពីខ្លឹមសារដីកានេះ ត្រូវចាត់ទុកជានិរាករណ៍ ។/.

# ជំពូកទី៥
# អវសានប្បញ្ញត្តិ

**ប្រការ១៤**.-

ដីកានេះមានសុពលភាពពេញលេញ ក្រោយពេលដែលក្រុមប្រឹក្សាស្រុកថ្មគោលបានប្រជុំពិភាក្សា ពិនិត្យ និងអនុម័តរួចរាល់ និងអស់សុពលភាពក្រោយពីក្រុមប្រឹក្សាធ្វើវិសោធនកម្ម ឬលុបចោលដីកានេះទាំងស្រុង ។

**ប្រការ១៥**.-

ក្រុមការងារ ការិយាល័យសាមី និងអង្គភាពពាក់ព័ន្ធរបស់រដ្ឋបាលស្រុកថ្មគោល ត្រូវចូលរួមផ្សព្វផ្សាយនូវខ្លឹមសារដីកាស្ដីពីការលើកកម្ពស់សុវត្ថិភាព និងសុខុមាលភាពចំណីអាហារនៅតាមគ្រឹះស្ថានសិក្សានិងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធទៅដល់សិស្សានុសិស្ស មាតាបិតាសិស្ស ឬអាណាព្យាបាលសិស្ស អ្នកលក់ចំណីអាហារ និងសហគមន៍ឲ្យបានទូលំទូលាយ ។

**ប្រការ១៦**.-

ក្រុមប្រឹក្សាស្រុក គណៈអភិបាលស្រុក ការិយាល័យ អង្គភាពពាក់ព័ន្ធ ក្រុមការងារទទួលបន្ទុករបស់រដ្ឋបាលស្រុក គណៈគ្រប់គ្រងគ្រឹះស្ថានសិក្សា លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស អ្នកលក់ចំណីអាហារក្នុងបរិវេណ និងជាប់ខាងក្រៅបរិវេណគ្រឹះស្ថានសិក្សា និងអ្នកពាក់ព័ន្ធផ្សេងទៀត ត្រូវចូលរួមអនុវត្តដីកានេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ព្រហស្បតិ៍ ៧រោច ខែមាឃ ឆ្នាំជូត ទោស័កពស ២៥៦៤

ថ្មគោល ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២១

**ជ.ក្រុមប្រឹក្សាស្រុក**

**ប្រធាន**

រ៉ឿន រ៉ាឌី

**កន្លែងទទួល៖**

- រដ្ឋបាលខេត្តបាត់ដំបង
- មន្ទីរសុខាភិបាល
  មន្ទីរអប់រំ យុវជន និងកីឡា
  "ដើម្បីជូនជ្រាប"
- ការិយាល័យអប់រំ យុវជន និងកីឡា
- ការិយាល័យស្រុកប្រតិបត្តិ
- មណ្ឌលសុខភាពសាមី
- រដ្ឋបាលឃុំទាំង១០
  "ដើម្បីសហការអនុវត្ត"
- គ្រឹះស្ថានសិក្សាដែលបានផ្ទេរ
  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ